ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី២២
## ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក

*****

តាមការអញ្ជើញរបស់លោកជំទាវ **ហ្វេដឺរីកា** ម៉ូហ្គេរីនី តំណាងជាន់ខ្ពស់សហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេស និងគោលនយោបាយសន្តិសុខ និងជាអនុប្រធានគណៈកម្មការអឺរ៉ុប **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំគណៈប្រតិភូកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុបលើកទី២២ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប គឺជាវេទិកាដ៏សំខាន់មួយសម្រាប់រដ្ឋមន្ត្រីមកពីប្រទេសសមាជិកអាស៊ាននិងសហភាពអឺរ៉ុបទាំងអស់ជួបពិភាក្សាអំពីបញ្ហារួមសម្រាប់កិច្ចសហប្រតិបត្តិការដែលផ្តល់ប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ក្នុងគោលដៅពង្រឹងនិងពង្រីកបន្ថែមនូវទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុប។ នៅក្នុងឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន-សហភាពអឺរ៉ុប លើកទី២២ ក្រៅពីការពិនិត្យឡើងវិញនូវការរីកចម្រើននៃកិច្ចសហប្រតិបត្តិការកន្លងមក រដ្ឋមន្ត្រីទាំងអស់បានពិភាក្សាអំពីទិសដៅអនាគតនៃកិច្ចសហប្រតិបត្តិការរបស់អាស៊ាននិងសហភាពអឺរ៉ុប និងការផ្លាស់ប្តូរទស្សនៈគ្នាផងដែរអំពីបញ្ហាបន្ទាន់ថ្មីៗជុំវិញពិភពលោក រួមមាន៖ បម្រែបម្រួលអាកាសធាតុ ការតភ្ជាប់ ការប្រឆាំងអំពើភេរវកម្ម សន្តិសុខលំហសមុទ្រ អន្តោប្រវេសន៍ និងពាណិជ្ជកម្ម ដែលជាបញ្ហាកង្វល់រួមរបស់តំបន់ទាំងពីរ ក៏ដូចជាសកលលោកផងដែរ។ រដ្ឋមន្ត្រីទាំងអស់បានបញ្ជាក់ឡើងវិញនូវតួនាទីដ៏មានសារៈសំខាន់របស់អាស៊ាន



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

និងសហភាពអឺរ៉ុបក្នុងការតម្រង់ទិសវិស័យនយោបាយ សង្គមសេដ្ឋកិច្ច និងរបៀបវារៈសន្តិសុខនៅតំបន់ទាំងពីរ និងពិភពលោក។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុបលើកទី២២នេះ បានអនុម័ត "**សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី២២**" ដែលអាស៊ាននិងសហភាពអឺរ៉ុបបានឯកភាពជាគោលការណ៍តម្លើងពីភាពជាដៃគូទូលំទូលាយ អាស៊ាន-សហភាពអឺរ៉ុប ទៅជាកម្រិត**ដៃគូយុទ្ធសាស្ត្រ** ដោយបន្តចរចាលើចំណុចលម្អិតនិងកាលបរិច្ឆេទច្បាស់លាស់ជាបន្តទៀត។

សហភាពអឺរ៉ុបបានអះអាងជាថ្មី នូវការគាំទ្រចំពោះតួនាទីស្នូលរបស់អាស៊ាននៅក្នុងនិមាបន្ទកម្មតំបន់ដែលកំពុងវិវត្តន៍ និងតួនាទីនាំមុខអាស៊ានក្នុងការជំរុញកិច្ចសន្ទនា សម្របសម្រួលនិងកិច្ចសហប្រតិបត្តិការដើម្បីសន្តិភាព សន្តិសុខ ស្ថិរភាព វិបុលភាព និងឈរលើមូលដ្ឋានច្បាប់ ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងក្រៅតំបន់។

ក្នុងការឆ្លើយតបក្នុងនាមអាស៊ាន លើរបៀបវារៈស្តីពីការតភ្ជាប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសំដែងនូវសេចក្តីរីករាយចំពោះការរួមចំណែកនិងការគាំទ្ររបស់សហភាពអឺរ៉ុប ចំពោះការតភ្ជាប់អាស៊ានជាពិសេសការចូលរួមរបស់សហភាពអឺរ៉ុប ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើការតភ្ជាប់អាស៊ានទាំងហេដ្ឋារចនាសម្ព័ន្ធរឹងនិងទន់ ដើម្បីគាំទ្រការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ តាមរយៈកិច្ចសន្ទនាតាមវិស័យ និងកិច្ចសហប្រតិបត្តិការអាស៊ាន-សហភាពអឺរ៉ុប ក្នុងបំណងពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអាស៊ាន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាកត្តាមួយដ៏សំខាន់ ដែលជាវិភាគទានមួយដ៏ចំបងសម្រាប់ការអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ផងដែរអំពីសារៈប្រយោជន៍នៃការបង្កើនការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និងការធ្វើសំយោគកម្មនៃផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងវិថី យុទ្ធសាស្ត្រ និងទស្សនទានឥណ្ឌូ-ប៉ាស៊ីហ្វិក ផែនការមេយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ និងក្របខណ្ឌវិនិយោគមហាអនុតំបន់មេគង្គ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ពីសារៈសំខាន់ក្នុងការបង្កើនកិច្ចខំប្រឹងប្រែងរួមរវាងអាស៊ាន និងសហភាពអឺរ៉ុប ក្នុងការចូលរួមដោះស្រាយការរីកលូតលាស់យឺតក្នុងសកលលោក ជាពិសេសតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីគ្រប់ជ្រុងជ្រោយរវាងតំបន់ និងតំបន់អាស៊ាន និងសហភាពអឺរ៉ុបដែលនឹងបង្កើនអ្នកប្រើប្រាស់កាន់តែច្រើន ពង្រីកទីផ្សារកាន់តែធំ បង្កើនការរីកលូតលាស់ និងកិច្ចអភិវឌ្ឍសម្រាប់តំបន់ទាំងពីរ។

រដ្ឋមន្ត្រីទាំងអស់ក៏បានផ្លាស់ប្តូរទស្សនៈគ្នាអំពីបញ្ហាតំបន់ និងអន្តរជាតិ រួមទាំងបញ្ហាប្រយុទ្ធប្រឆាំងភេរវកម្ម និងអំពើជ្រុលនិយមហឹង្សា និងបញ្ហាឧបទ្វីបកូរ៉េ ផងដែរ។

ពាក់ព័ន្ធនឹងបញ្ហាឧបទ្វីបកូរ៉េ រដ្ឋមន្ត្រីទាំងអស់បានសំដែងការប្តេជ្ញាគាំទ្រនូវដំណោះស្រាយគ្រប់ជ្រុងជ្រោយ តាមរយៈការទូតនិងការអនុវត្តពេញលេញនូវសេចក្តីសម្រេចចិត្តពាក់ពន្ធ័នានារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ រដ្ឋមន្ត្រីទាំងអស់ក៏បានគូសបញ្ជាក់ផងដែរថា ការវិវត្តន៍នៃទំនាក់ទំនងអន្តរកូរ៉េ ការលុបបំបាត់អាវុធនុយក្លេអែរទាំងស្រុងដែលអាចផ្ទៀងផ្ទាត់បាន និងមិនអាចប្រែក្រឡាស់ ព្រមទាំងសន្តិភាពនៅឧបទ្វីបកូរ៉េ គឺមានសារៈសំខាន់សម្រាប់សន្តិភាព សន្តិសុខ និងស្ថិរភាព នៅអាស៊ីបូព៌ានិងពិភពលោកទាំងមូល។ រដ្ឋមន្ត្រីទាំងអស់ក៏បានស្វាគមន៍នូវកិច្ចខិតខំប្រឹងប្រែងរបស់សាធារណរដ្ឋកូរ៉េ និងគំនិតផ្តួចផ្តើមការទូតនានាពីដៃគូផ្សេងៗ ដើម្បីសម្រេចគោលដៅទាំងនេះ។

ឆ្លៀតក្នុងឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន-សហភាពអឺរ៉ុបលើកទី២២ នេះដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏មានជំនួបទ្វេភាគីដោយឡែកពីគ្នាជាមួយ**ឯកឧត្តម ឌីឌៀរ រ៉េនឌ័រ** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងកិច្ចការអឺរ៉ុបប្រទេសបែលហ្សិក **លោកជំទាវ សេស៊ីលីយ៉ា ម៉ាលស្ត្រុម**ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប និង**ឯកឧត្តម អេនតូនីញ៉ូ លូប៉េស អ៊ីសទូរីស** សមាជិកសភាអឺរ៉ុប មកពីប្រទេសអេស្ប៉ាញ និងជាអគ្គលេខាធិការគណបក្សប្រជាជនអឺរ៉ុប ៕

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៩